**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មហាអយ្យការអមសាលាឧទ្ធរណ៍**

លេខ...៤.២៦...អ.ឃ.ក..|.១៨

## ដីកាសម្រេចបង្គាប់អោយបង្កកទ្រព្យសម្បត្តិ និងមូលនិធិ

## យើងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

**បានឃើញ** ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០០៧/០១៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ។

**បានឃើញ** ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ។

**បានឃើញ** ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៦ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ ។

**បានឃើញ** អនុក្រឹត្យលេខ ៩០ អ.ន.ក្រ.ប.ក ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៤ ស្តីពីការបង្កកទ្រព្យសម្បត្តិរបស់ភេរវករ និងអង្គការនានា ។

យោងលិខិតលេខ ០៧៤៣ ក.យ.រ.ប/១៨ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**<u>សម្រេច</u>**

១.បង្គាប់មកបុគ្គលរាយការណ៍ និងបុគ្គលផ្សេងទៀត អោយបង្កកទ្រព្យសម្បត្តិ និងមូលនិធិទាំងឡាយរបស់បុគ្គល ដែលមានរាយឈ្មោះក្នុងបញ្ជីអាល់កៃដា និងតាលីបង់ ដូចបានជូនភ្ជាប់មកជាមួយជាបន្តបន្ទាប់តាមសេចក្តីសម្រេចលេខ **១២៦៧** របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។

២.រាយការណ៍មកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាបន្ទាន់ ក្រោយពីបានបង្កកទ្រព្យសម្បត្តិ និងមូលនិធិទាំងនេះរួច ដើម្បីបានជាមូលដ្ឋានក្នុងការចាត់វិធានការតាមច្បាប់តទៅ ។

ថ្ងៃសុក្រ ០៥រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨

**អគ្គព្រះរាជអាជ្ញា**

អ៊ុក_សាវុធ